**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ៖៣១
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤
សាលក្រមរដ្ឋប្បវេណីលេខ៖ ៣១ "ត"
ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តត្បូងឃ្មុំ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ម៉ោង ២រសៀល
ដោយមានសមាសភាពដូចតទៅ

**ចៅក្រមជំនុំជម្រះ**

*ឯកឧត្តម [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ*

**ក្រឡាបញ្ជីសវនាការ**

*លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ*

**ដើមចោទ**

ឈ្មោះ [redacted]សុជានី ភេទស្រី កើតថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩២ ជនជាតិខ្មែរ មានទីកន្លែងកំណើត កើតនៅភូមិ[redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]។

*មេធាវីតំណាងដោយអាណត្តិ៖* លោក [redacted] អត្តលេខ១៤៣៤ និងលោក [redacted] អត្តលេខ២៦៨៥ T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីក្រុមហ៊ុនមេធាវី ហនុមាន និងសហការី ដែលមានការិយាល័យសាខាស្ថិតនៅផ្ទះលេខ[redacted]ជាមេធាវីតំណាងឱ្យដើមចោទ។

**និងចុងចម្លើយ**

ឈ្មោះ [redacted] ចាន់វិទ្ធថា ភេទប្រុស កើតថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៤ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ[redacted] មានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]មុខរបរកសិករ។

<u>**អង្គហេតុ និងចំណុចវិវាទ**</u>

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ស្នើសុំឱ្យសាលាដំបូងចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.ទទួលស្គាល់ការលែងលះ និងរំលាយសំបុត្រអាពាហ៍ពិពាហ៍លេខ:៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយលោក [redacted] ចាន់ណារុន មន្ត្រីអត្រានុកូលដ្ឋានស្រុកកំពង់សៀម រវាងឈ្មោះ [redacted] សុជានី និងឈ្មោះ [redacted] ចាន់វិទ្ធថា។

២.ប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទលើកូនឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស អាយុ៥ឆ្នាំ កើតនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលមានសំបុត្រកំណើតលេខ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយលោកស្រី [redacted] សុគន្ធា មន្ត្រីអត្រានុកូលដ្ឋានស្រុកត្បូងឃ្មុំ។



Scanned with CamScanner

## ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១-ការសង្ខេបអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលមានលេខៈ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអំពិល ស្រុកកំពង់សៀម។ អំឡុងពេលបានរួមរស់នៅជាមួយគ្នាដើមចោទ និងចុងចម្លើយ បានបង្កើតបានកូនចំនួន១នាក់ មានឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស កើតនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ ២០១៨ ដែលមានសំបុត្រកំណើតលេខៈ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំជីរោទ៍ទី១ ស្រុកត្បូងឃ្មុំ។ ក្នុងអំឡុងពេលរួមរស់ជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយពុំមានទ្រព្យរួម និងមានបំណុលរួមគ្នានោះទេ។ ក្រោយពីរៀបការរួចដើមចោទ និងចុងចម្លើយ តែងតែមានទំនាស់នឹងគ្នា ដោយចុងចម្លើយធ្លាប់ប្រើប្រាស់គ្រឿងញៀន ហើយធ្លាប់បានជាប់ពន្ធនាគារ និងធ្លាប់ប្រើអំពើហិង្សាមកលើដើមចោទជារឿយៗ ចុងចម្លើយមិនដែលផ្តល់ភាពកក់ក្តៅដល់គ្រួសារនោះទេ ហើយសព្វថ្ងៃនេះគឺចុងចម្លើយពុំមានមុខរបរពិតប្រាកដនោះទេ។ ថ្មីៗនេះចុងចម្លើយតែងតែរករឿងដើមចោទ ដោយធ្លាប់បានគំរាមថានឹងសម្លាប់ដើមចោទទៀតផង មូលហេតុទាំងនេះធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្រពន្ធប្តីទៀតហើយ ហើយបានដាក់ពាក្យប្តឹងមកកាន់តុលាការ ដើម្បីសុំសាលក្រមលែងលះស្របតាមច្បាប់។

### ខ.២-អង្គហេតុដែលគ្មានវិវាទ

១-ដើមចោទ និងចុងចម្លើយទទួលស្គាល់ថាបានរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាមួយគ្នាត្រឹមត្រូវនៅឆ្នាំ២០១៨។

### ខ.៣-ចំណុចវិវាទ

១-តើមានអត្ថិភាព ឬនត្ថិភាព ដែលជាមូលហេតុនៃការលែងលះស្របតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីដែរឬទេ ?

២-ដើមចោទ និងចុងចម្លើយ តើភាគីណាមួយដែលមានគុណសម្បត្តិក្លាយជាអ្នកគ្រប់គ្រងកូនមួយនាក់នេះ?

### ខ.៤-ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

*-ការអះអាងរបស់ដើមចោទ*

ដើមចោទឈ្មោះ [redacted] សុដានី បានថ្លែងការណ៍ថាៈ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ជាមួយឈ្មោះ [redacted] ចាន់រិទ្ធថា ភេទប្រុស អាយុ ៣០ឆ្នាំ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអំពិល ស្រុកកំពង់សៀម។ អំឡុងពេលបានរួមរស់នៅជាមួយគ្នា នាងខ្ញុំនិងស្វាមី បានបង្កើតបានកូនចំនួនមួយនាក់ មានឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស កើតនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ ២០១៨ ដែលមានសំបុត្រកំណើតលេខ ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំជីរោទ៍ទី១ ក្នុងអំឡុងពេលរួមរស់ជាប្តីប្រពន្ធ នាងខ្ញុំនិងស្វាមី ពុំមានទ្រព្យរួម និងពុំមានបំណុលរួមគ្នានោះទេ។

ក្រោយពីរៀបការរួច នាងខ្ញុំនិងស្វាមី តែងតែមានទំនាស់នឹងគ្នា ប្តីនាងខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀន ហើយធ្លាប់បានជាប់ពន្ធនាគារ គាត់ធ្លាប់ប្រើអំពើហិង្សាមកលើនាងខ្ញុំជារឿយៗ គាត់មិនដែលផ្តល់



Scanned with CamScanner

ភាពកក់ក្តៅដល់គ្រួសារនោះទេ ហើយសព្វថ្ងៃនេះគឺគាត់ពុំមានមុខរបរពិតប្រាកដនោះទេ។ ថ្មីៗនេះគាត់តែងតែរករឿងនាងខ្ញុំ ដោយធ្លាប់បានគំរាមថានឹងសម្លាប់នាងខ្ញុំទៀតផង មូលហេតុទាំងនេះធ្វើអោយនាងខ្ញុំអស់មនោសញ្ចេតនាជាប្រពន្ធប្តីទៀតហើយ។

នាងខ្ញុំសូមបញ្ជាក់មូលហេតុចាំបាច់នៃការទាមទារនីមួយៗដូចខាងក្រោម៖

ការទាមទារចំណុចទី១៖ ទទួលស្គាល់ការលែងលះ និងរំលាយសំបុត្រអាពាហ៍ពិពាហ៍លេខ ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអំពិល ស្រុកកំពង់សៀម រវាងឈ្មោះ [redacted] ចាន់វិទ្ធថា និងឈ្មោះ [redacted] សុដានី ដោយហេតុថាៈ ស្វាមីនាងខ្ញុំតែងតែរករឿងឈ្លោះជាមួយនាងខ្ញុំ គាត់ធ្លាប់ជាប់ពន្ធនាគារដោយសារប្រើប្រាស់គ្រឿងញៀន ហើយពេលនេះបានចេញពីពន្ធនាគារវិញ តែគាត់ក៏នៅតែប្រើប្រាស់គ្រឿងញៀនផងដែរ សព្វថ្ងៃនេះគាត់ពុំមានមុខរបរពិតប្រាកដនោះទេ។ គាត់តែងតែបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះជាច្រើនលើកច្រើនសារ ដេរប្រមាថមើលងាយនាងខ្ញុំ ជាពិសេសគាត់តែងតែប្រើអំពើហិង្សាមកលើនាងខ្ញុំជាច្រើនលើកច្រើនសារ កន្លងមកថែមទាំងធ្លាប់ប្រើពាក្យសម្តីថានឹងសម្លាប់នាងខ្ញុំទៀតផង ទង្វើទាំងអស់នេះធ្វើឱ្យនាងខ្ញុំ អស់មនោសញ្ចេតនានឹងគ្នា និងមិនអាចបន្តទ្រាំរួមរស់ជាមួយគ្នាតទៅទៀតបានទេ។

ការទាមទារចំណុចទី២៖ ប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទ លើកូន១នាក់ដោយហេតុថាៈ ចុងចម្លើយពុំដែលផ្តល់ភាពកក់ក្តៅ ពេលវេលា ដល់កូនក្នុងនាមជាឪពុកឡើយ ដោយសារចុងចម្លើយពុំសូវនៅផ្ទះទេ គាត់តែងតែទៅក្រៅជាមួយមិត្តភក្តិសេពគ្រឿងញៀន គ្មានលទ្ធភាពចិញ្ចឹមកូននោះទេ ហើយបច្ចុប្បន្ននេះគាត់ពុំមានការងារច្បាស់លាស់នោះទេ។ ដោយមូលហេតុទាំងអស់នេះនាងខ្ញុំព្រួយបារម្ភអំពីអនាគតកូននៅតូច ហេតុនេះទើបនាងខ្ញុំ សុំឱ្យតុលាការសម្រេចផ្តល់សិទ្ធិអំណាចមេបាឱ្យនាងខ្ញុំលើកូនចំនួនមួយនាក់ដូចបានរៀបរាប់ខាងលើ។ កូនខ្លួននៅតូច ត្រូវការរៀនសូត្រតទៅមុខ មានអនាគតវែងឆ្ងាយ ពេលនេះកូនខ្លួននៅជាមួយម្តាយក្មេក ព្រោះពេលការរួច គឺខ្លួននៅជាមួយម្តាយក្មេក ហើយបានម្តាយក្មេកជួយមើលថៅពិតមែន ប៉ុន្តែការផ្គត់ផ្គង់គឺខ្លួនជាអ្នកផ្គត់ផ្គង់ទាំងអស់ ព្រោះសព្វថ្ងៃនេះខ្លួនជាគ្រូពេទ្យឆ្មប នៅមណ្ឌលសុខភាពទន្លេបិទ (ស្រុកត្បូងឃ្មុំ)។

-លោក [redacted] អត្តលេខ១៤៣៤ និងលោក [redacted] អត្តលេខ២៦៨៥ T ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ ពុំមានសេចក្តីថ្លែងការណ៍បន្ថែមទៀតនោះទេ គឺរក្សាការអះអាងរបស់កូនក្តីខ្លួនទុកដដែល។

*ការអះអាងតបរបស់ចុងចម្លើយ*

-ចុងចម្លើយឈ្មោះ [redacted] ចាន់វិទ្ធថា បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ទាក់ទងនឹងការទាមទារលែងលះ ខ្ញុំបាទមិនព្រមលែងលះពីដើមចោទតាមការទាមទារនោះទេ ខ្ញុំនៅស្រឡាញ់គាត់ជាប្រពន្ធ និងអាណិតកូនដែលនៅតូច មិនចង់ឱ្យកំព្រាឪពុកម្តាយ។ មូលហេតុដែលខ្លួនមិនចង់លែងលះពីចុងចម្លើយព្រោះខ្លួនមិនដែលធ្វើបាបឬរករឿងប្រពន្ធខ្ញុំនោះទេ។ ពីមុនមកខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាធ្លាប់ជាប់ពន្ធនាគារពិតមែន ហើយអំឡុងពេលរៀបការរួច គឺខ្ញុំតែងតែខិតខំរកស៊ីចិញ្ចឹមប្រពន្ធកូនជានិច្ច ដោយខ្ញុំរកស៊ីចិញ្ចឹមសត្វមាន់។ ពេលលក់សត្វមាន់បានលុយម្តងៗ គឺខ្លួនតែប្រគល់ជូនប្រពន្ធ របស់ខ្លួនជាអ្នកទុកដាក់ជានិច្ច។ ខ្លួនមិនដែលប្រើអំពើហិង្សាដាក់ប្រពន្ធខ្លួននោះទេ គ្រាន់តែមានការទាស់ទែងពាក្យសម្តីបន្តិចបន្តួចក្នុងគ្រួសារប៉ុណ្ណោះ។ ពេលនេះខ្លួនរស់នៅបែកលំនៅឋានគ្នាជិត១ឆ្នាំមកហើយ។ ខ្លួនពីមុនមកពិតជាធ្លាប់



Scanned with CamScanner

ប្រើប្រាស់គ្រឿងញៀនពិតមែន ប៉ុន្តែពេលនេះខ្លួនឈប់ប្រើប្រាស់យូរហើយ។ ចំពោះល្បែងខ្លួនក៏ធ្លាប់លេង ផងដែរពីមុនមក ប៉ុន្តែពេលនេះខ្លួនឈប់លេងយូរហើយ។ ពីមុនមកខ្លួនជាប់ពន្ធនាគារចំនួន២ដងមក ហើយ ដោយជាប់លើកទី១ ចំនួន ២ឆ្នាំ និងជាប់លើកទី២ ចំនួន ១ឆ្នាំ នៅពន្ធនាគារខេត្តត្បូងឃ្មុំ។ ខ្លួន ធ្លាប់ឱ្យលុយកាក់ប្រពន្ធខ្លួនចាយផងដែ ប៉ុន្តែគាត់ថា ខ្ញុំមិនដែលឱ្យគាត់ចាយទៅវិញ។ ខ្ញុំសំណូមពរតុលា-ការដើម្បីធ្វើការផ្សះផ្សារជាមួយប្រពន្ធមួយរយៈសិន បើមិនត្រូវគ្នា ខ្លួនសុខចិត្តឱ្យគេលែងលះពីខ្ញុំចុះ។ ចំពោះមុខរបររកស៊ីសព្វថ្ងៃ ខ្លួនចិញ្ចឹមមាន់ជាច្រើនផងដែរ មិនមែនចិញ្ចឹម ២ទៅ ៣ក្បាល ដូចការអះអាង របស់ដើមចោទនោះទេ។

ខ្លួនមិនព្រមប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទ លើកូន១នាក់ដោយហេតុថាៈ ដើមចោទពុំ ដែលផ្តល់ភាពកក់ក្តៅ និងពេលវេលាដល់កូនក្នុងនាមជាម្តាយឡើយ ដោយសារដើមចោទពុំសូវនៅផ្ទះទេ ហើយពេលកូនឈឺគឺគាត់មិនដែលនៅផ្ទះនោះទេ តែងតែទុកកូនឱ្យម្តាយខ្លួនអ្នកមើលរហូត។ បច្ចុប្បន្ននេះ ខ្លួនក៏មានការងារច្បាស់លាស់ ហើយអាចចិញ្ចឹមកូនឈ្មោះ [redacted] ចាន់មុនីរាជ ឱ្យបានរៀនសូត្រមានអនា គត។ សព្វថ្ងៃនេះកូនប្រុសខ្លួន កំពុងតែរស់នៅជាមួយម្តាយខ្លួនផងដែរ ដែលគាត់ជួយចិញ្ចឹមតាំងពីតូចមក ហេតុនេះខ្លួនស្នើសុំឱ្យតុលាការសម្រេចផ្តល់សិទ្ធិអំណាចមេបាលើកូននេះឱ្យ ខ្ញុំបាទជាអ្នកគ្រប់គ្រងថែរក្សា ដូចបានរៀបរាប់ខាងលើ។

ខ្លួនសូមបញ្ជាក់ថា ឈ្មោះ [redacted] សុជានី ពុំដែលមានពេលវេលាគ្រប់គ្រាន់ដើម្បីមើលថែកូនរបស់ ខ្លួននោះទេ ព្រោះឈ្មោះ [redacted] សុជានី មិនសូវនៅមើលថែកូន ហើយតែងតែចាកចោលផ្ទះ មិនដែលនៅ មើលថែកូនពេលកូនឈឺ ហើយចំណុចដែលឈ្មោះ [redacted] សុជានី ថាជាអ្នកផ្គត់ផ្គង់ចិញ្ចឹមកូនតែឯងនោះ គឺមិនពិតនោះទេ ពោលគឺខ្លួនតែផ្តល់លុយកាក់ចិញ្ចឹមកូនជានិច្ចមិនដែលអាក់ខានឡើយ។ កន្លងមក ក្រោយរៀបការ គឺខ្លួនតែងផ្តល់លុយកាក់ជូនប្រពន្ធខ្លួនទុកដាក់រហូត មិនដែលអាក់ខាននោះឡើយ។ និយាយរួម រឿងដែលដើមចោទអះអាង គឺខ្លួនសូមបដិសេធចោលទាំងស្រុង ខ្លួនមិនដែលគំរាមកំហែងរក សម្លាប់ ឬ ប្រើអំពើហិង្សាលើប្រពន្ធរបស់ខ្លួននោះទេ។

*ការអះអាងតបបន្ថែមរបស់ដើមចោទៈ*

មូលហេតុពេលខ្លះដែលខ្លួនមិនសូវបាននៅក្បែរកូនខ្លួន ពេលនោះប្តីខ្លួនឈ្មោះ [redacted] ចាន់រិទ្ធថា បានមានជម្លោះក្នុងគ្រួសារជាមួយខ្លួន តែងតែធ្វើបានខ្លួនទាំងផ្លូវកាយ ផ្លូវចិត្ត ដូចជាគាត់គិតតែដើរលេង ដាច់យប់ មិនដែលប្រាប់ប្រពន្ធនោះទេ ធ្វើឱ្យខ្លួនគិតច្រើន ពិបាកចិត្តរហូត។ ពេលដែលខ្លួនសួរនាំគាត់ គឺ គាត់តែងតែប្រើហិង្សាវាយដំមកលើខ្លួន ហើយផ្នែកសេដ្ឋកិច្ច គឺគាត់តែងតែដុតរបស់របរក្នុងផ្ទះ បោករបស់ របរក្នុងផ្ទះ បំផ្លាញនេះបំផ្លាញនោះរហូត។

-លោក [redacted] ច័ន្ទវាសនា អត្តលេខ១៤៣៤ តំណាងដោយអាណត្តិឱ្យដើមចោទៈ ខ្លួនសូមរក្សាការ អះអាងរបស់កូនក្តីខ្លួនទុកដដែល។ ខ្លួនសូមបន្ថែមចំណុចទី២ គឺកូនក្តីខ្លួនមានមុខរបរច្បាស់លាស់ មាន ការងារត្រឹមត្រូវ ដែលអាចចិញ្ចឹមកូនឱ្យរៀនសូត្របានល្អនាពេលអនាគត ហើយអាចផ្តល់ភាពកក់ក្តៅជូន កូនបានផងដែរ។ កូនក្តីខ្លួនជាគ្រូពេទ្យ ជាអ្នកមានចំណេះដឹងមួយរូប ដែលអាចទូន្មានកូនបានល្អប្រសើរ ហើយអាចមើលថែកូនបានយូរអង្វែង ដោយកូនក្តីខ្លួនមិនដែលបានប្រព្រឹត្តបទល្មើសក្នុងសង្គមនោះទេ។ ចំណែកចុងចម្លើយមានប្រវត្តិធ្លាប់ជាប់ពន្ធនាគារ មានការងារមិនច្បាស់លាស់ ចូលចិត្តប្រើអំពើហិង្សាក្នុង



Scanned with CamScanner

គ្រួសារ ហើយលទ្ធភាពជីវភាពនូវមានកម្រិត មិនអាចដាក់កូនឱ្យចូលរៀននៅសាលាល្អបាននោះទេ។ ហេតុនេះ ខ្លួនស្នើសុំតុលាការចេញសាលក្រមផ្តល់កូននោះ មកឱ្យកូនក្តីខ្លួនជាអ្នកមានអំណាចមេបាផងចុះ ។

**គ.ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

*គ.១ ឆ្លើយតបនិងការទាមទារត្រង់ចំណុចវិវាទ ដើមចោទសូមថ្លែងការណ៍ដូចតទៅ ៖*

-ខ្លួនចង់លែងលះពីចុងចម្លើយ ព្រោះចុងចម្លើយមិនសូវផ្តល់សុភមង្គលមកឱ្យខ្លួន និងតែងតែមានភាពរកាំរកូសក្នុងគ្រួសារញឹកញាប់ ហើយថែមទាំងបានប្រើអំពើហិង្សាមកលើខ្លួនថែមទៀតផង។

-ពេលនេះខ្លួនបានរស់នៅបែកលំនៅឋានគ្នាប្រហែល ១ឆ្នាំមកហើយ។

-ពាក់ព័ន្ធនឹងកូនម្នាក់ឈ្មោះ [redacted] ចាន់មុនីរាជ គឺខ្លួនសូមសិទ្ធិជាអ្នកមានអំណាចមេបា ព្រោះខ្លួនស្រឡាញ់កូន និងមានលទ្ធភាពចិញ្ចឹមកូនបានល្អ។

-ចំពោះប្រាក់ប្រដាប់ក្តីសុំអោយតុលាការពិចារណាតាមច្បាប់ ដោយសារកើតចេញពីកំហុសភាគីចុងម្លើយ។

*គ.២ ឆ្លើយតបនិងការទាមទារត្រង់ចំណុចវិវាទ ដើមចោទសូមថ្លែងការណ៍ដូចតទៅ ៖*

-ខ្លួនមិនព្រមលែងលះពីដើមចោទនោះទេ ព្រោះខ្លួននៅស្រឡាញ់ដើមចោទ ហើយអាណិតកូន។

-ពាក់ព័ន្ធនឹងកូនម្នាក់ឈ្មោះ [redacted] ចាន់មុនីរាជ គឺខ្លួនសូមសិទ្ធិជាអ្នកមានអំណាចមេបា ព្រោះខ្លួនស្រឡាញ់កូន និងមានលទ្ធភាពចិញ្ចឹមកូនបានល្អ។

-ចំពោះប្រាក់ប្រដាប់ក្តីសុំអោយតុលាការពិចារណាតាមច្បាប់ ដោយសារកើតចេញពីកំហុសភាគីដើមចោទ។

**ឃ-<u>អំពីភស្តុតាង៖</u>**

-ពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ។

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខៈ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់លោក [redacted] ចាន់ណារុន មន្ត្រីអត្រានុកូលដ្ឋានស្រុកកំពង់សៀម ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ០៦១៣៦១១៥៧ (០១) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុដានី។

-សំបុត្រកំណើតលេខ ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ ដារ៉ា ចាន់មុនីរាជ និងឯកសារផ្សេងៗទៀតក្នុងសំណុំរឿង។

**<u>សំអាងហេតុ</u>**

**ក-ស្តីពីចំណុចវិវាទ**

យោងតាមពាក្យបណ្តឹង, សំបុត្រអាពាហ៍ពិពាហ៍លេខ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ០៦១៣៦១១៥៧ (០១) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុដានី, សំបុត្រកំណើតលេខៈ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ចាន់មុនីរាជ និងឯកសារផ្សេងៗទៀតក្នុងសំណុំរឿង ព្រមទាំងតាមការឆ្លើយរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការទទួលស្គាល់ថា ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ត្រឹមត្រូវតាមច្បាប់ ហើយក្រោយពេលរៀបការអ្នកទាំងពីរមានកូនចំនួន ១នាក់



Scanned with CamScanner

ហើយពុំមានសល់ទ្រព្យសម្បត្តិរួមនោះទេ ដូចមានចែងក្នុងមាត្រា៩៥៥, មាត្រា៩៨២ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី រួមជាមួយនឹងស្មារតីនៃមាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវយកមកអនុវត្តផងដែរ។

**ខ-ការវិនិច្ឆ័យអំពីមូលហេតុនៃការលែងលះ**

១-តាមរយៈការឆ្លើយរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានអះអាងថា: នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ជាមួយឈ្មោះ [redacted] ចាន់វិទ្ធថា ភេទប្រុស អាយុ៣០ឆ្នាំ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអំពិល ស្រុកកំពង់សៀម។ អំឡុងពេលបានរួមរស់នៅជាមួយគ្នា នាងខ្ញុំនិងស្វាមី បានបង្កើតបានកូនចំនួនមួយនាក់ មានឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស កើតនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ ២០១៨ ដែលមានសំបុត្រកំណើតលេខ ១០១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំជីរោទ៍ទី១ ក្នុងអំឡុងពេលរួមរស់ជាប្ដីប្រពន្ធ នាងខ្ញុំនិងស្វាមី ពុំមានទ្រព្យរួម និងពុំមានបំណុលរួមគ្នានោះទេ។

ក្រោយពីរៀបការរួច នាងខ្ញុំនិងស្វាមី តែងតែមានទំនាស់នឹងគ្នា ប្ដីនាងខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀន ហើយធ្លាប់បានជាប់ពន្ធនាគារ គាត់ធ្លាប់ប្រើអំពើហិង្សាមកលើនាងខ្ញុំជារឿយៗ គាត់មិនដែលផ្ដល់ភាពកក់ក្ដៅដល់គ្រួសារនោះទេ ហើយសព្វថ្ងៃនេះគឺគាត់ពុំមានមុខរបរពិតប្រាកដនោះទេ។ ថ្មីៗនេះគាត់តែងតែរករឿងនាងខ្ញុំ ដោយធ្លាប់បានគំរាមថានឹងសម្លាប់នាងខ្ញុំទៀតផង មូលហេតុទាំងនេះធ្វើអោយនាងខ្ញុំអស់មនោសញ្ចេតនាជាប្រពន្ធប្ដីទៀតហើយ ។

ខ្លួនសុំតុលាការទទួលស្គាល់ការលែងលះ និងរំលាយសំបុត្រអាពាហ៍ពិពាហ៍លេខ ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអំពិល ស្រុកកំពង់សៀម រវាងឈ្មោះ [redacted] ចាន់វិទ្ធថា និងឈ្មោះ [redacted] សុជានី ដោយហេតុថា: ស្វាមីនាងខ្ញុំតែងតែរករឿងឈ្លោះជាមួយនាងខ្ញុំ គាត់ធ្លាប់ជាប់ពន្ធនាគារដោយសារប្រើប្រាស់គ្រឿងញៀន ហើយពេលនេះបានចេញពីពន្ធនាគារវិញ តែគាត់ក៏នៅតែប្រើប្រាស់គ្រឿងញៀនផងដែរ សព្វថ្ងៃនេះគាត់ពុំមានមុខរបរពិតប្រាកដនោះទេ។ គាត់តែងតែបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះជាច្រើនលើកច្រើនសារ ជេរប្រមាថមើលងាយនាងខ្ញុំ ជាពិសេសគាត់តែងតែប្រើអំពើហិង្សាមកលើនាងខ្ញុំជាច្រើនលើកច្រើនសារ កន្លងមកថែមទាំងធ្លាប់ប្រើពាក្យសម្ដីថានឹងសម្លាប់នាងខ្ញុំទៀតផង ទង្វើទាំងអស់នេះធ្វើឱ្យនាងខ្ញុំ អស់មនោសញ្ចេតនានឹងគ្នា និងមិនអាចបន្តទៅរួមរស់ជាមួយគ្នាតទៅទៀតបានទេ ។

ខ្លួនសូមបញ្ជាក់បន្ថែមថា មូលហេតុពេលខ្លះដែលខ្លួនមិនសូវបាននៅក្បែរកូនខ្លួន ពេលនោះប្ដីខ្លួនឈ្មោះ [redacted] ចាន់វិទ្ធថា បានមានជម្លោះក្នុងគ្រួសារជាមួយខ្លួន តែងតែធ្វើបានខ្លួនទាំងផ្លូវកាយ ផ្លូវចិត្ត ដូចជាគាត់គិតតែដើរលេងដាច់យប់ មិនដែលប្រាប់ប្រពន្ធនោះទេ ធ្វើឱ្យខ្លួនគិតច្រើន ពិបាកចិត្តរហូត។ ពេលដែលខ្លួនសួរនាំគាត់ គឺគាត់តែងតែប្រើហិង្សាវាយដំមកលើខ្លួន ហើយផ្នែកសេដ្ឋកិច្ច គឺគាត់តែងតែដុតរបស់របរក្នុងផ្ទះ បោករបស់របរក្នុងផ្ទះ បំផ្លាញនេះបំផ្លាញនោះរហូត។

២-ភាគីចុងចម្លើយបានថ្លែងការណ៍ថា: ទាក់ទងនឹងការទាមទារលែងលះ ខ្ញុំបាទមិនព្រមលែងលះពីដើមចោទតាមការទាមទារនោះទេ ខ្ញុំនៅស្រឡាញ់គាត់ជាប្រពន្ធ និងអាណិតកូនដែលនៅតូច មិនចង់ឱ្យ



Scanned with CamScanner

កំព្រាឪពុកម្តាយ។ មូលហេតុដែលខ្លួនមិនចង់លែងលះពីចុងចម្លើយ ព្រោះខ្លួនមិនដែលធ្វើបាបឬករឿងប្រពន្ធខ្ញុំនោះទេ។ ពីមុនមកខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាធ្លាប់ជាប់ពន្ធនាគារពិតមែន ហើយអំឡុងពេលរៀបការរួច គឺខ្ញុំតែងតែខិតខំរកស៊ីចិញ្ចឹមប្រពន្ធកូនជានិច្ច ដោយខ្ញុំរកស៊ីចិញ្ចឹមសត្វមាន់។ ពេលលក់សត្វមាន់បានលុយម្តងៗ គឺខ្លួនតែប្រគល់ជូនប្រពន្ធរបស់ខ្លួនជាអ្នកទុកដាក់ជានិច្ច។ ខ្លួនមិនដែលប្រើអំពើហិង្សាដាក់ប្រពន្ធខ្លួននោះទេ គ្រាន់តែមានការទាស់ទែងពាក្យសម្តីបន្តិចបន្តួចក្នុងគ្រួសារប៉ុណ្ណោះ។ ពេលនេះខ្លួនរស់នៅបែកលំនៅឋានគ្នាជិត ១ឆ្នាំមកហើយ។ ខ្លួនពីមុនមកពិតជាធ្លាប់ប្រើប្រាស់គ្រឿងញៀនពិតមែន ប៉ុន្តែពេលនេះខ្លួនឈប់ប្រើប្រាស់យូរហើយ។ ចំពោះល្បែង ខ្លួនក៏ធ្លាប់លេងផងដែរពីមុនមក ប៉ុន្តែពេលនេះខ្លួនឈប់លេងយូរហើយ។ ពីមុនមកខ្លួនជាប់ពន្ធនាគារចំនួន ២ដងមកហើយ ដោយជាប់លើកទី១ ចំនួន ២ឆ្នាំ និងជាប់លើកទី២ ចំនួន ១ឆ្នាំ នៅពន្ធនាគារខេត្តត្បូងឃ្មុំ។ ខ្លួនធ្លាប់ឱ្យលុយកាក់ប្រពន្ធខ្លួនចាយផងដែរ ប៉ុន្តែគាត់ថា ខ្ញុំមិនដែលឱ្យគាត់ចាយទៅវិញ។ ខ្ញុំសំណូមពរតុលាការដើម្បីធ្វើការផ្សះផ្សារជាមួយប្រពន្ធមួយរយៈសិន បើមិនត្រូវគ្នា ខ្លួនសុខចិត្តឱ្យគេលែងលះពីខ្ញុំចុះ។ ចំពោះមុខរបររកស៊ីសព្វថ្ងៃខ្លួនចិញ្ចឹមមាន់ជាច្រើនផងដែរ មិនមែនចិញ្ចឹម ២ ទៅ ៣ក្បាល ដូចការអះអាងរបស់ដើមចោទនោះទេ។

តាមរយៈការអះអាងនេះបញ្ជាក់បានថា ចុងចម្លើយបានទទួលស្គាល់នូវអត្ថិភាព នៃអាពាហ៍ពិពាហ៍ និងមានកូនក្នុងបន្ទុក។ នៅក្នុងដំណើរការនីតិវិធីតុលាការបានព្យាយាមធ្វើការផ្សះផ្សាដើម្បីឱ្យភាគីត្រូវរ៉ូវគ្នាវិញ តែភាគីមិនមានឆន្ទៈសះជានឹងគ្នាទេ ហើយក៏សម្រេចបន្តនីតិវិធីធម្មតា ក៏ប៉ុន្តែផ្អែកតាមការថ្លែងការណ៍របស់ភាគីទាំងសងខាង តុលាការយល់ថា ទំនាក់ទំនងជាប្តីប្រពន្ធរបស់ភាគី គឺមិនអាចស្តារឡើងវិញបានទេ ហើយដែលចំណុចនេះគឺចូលជាមូលហេតុនៃការលែងលះ ដូចមានចែងក្នុងមាត្រា៩៧៨ ចំណុច "ឃ" ដែលសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ និងចំណុច "ង" គឺក្នុងករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍-ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ ហេតុដូច្នេះគប្បីតុលាការត្រូវទទួលស្គាល់នូវអង្គហេតុ និងអត្ថិភាពនៃមូលហេតុនៃការលែងលះលើការថ្លែងការណ៍របស់ភាគីក្នុងការបញ្ជាប់ចំណងអាពាហ៍ពិពាហ៍ និងភស្តុតាងផ្សេងទៀត។

**គ-ការវិនិច្ឆ័យអំពីការកំណត់អ្នកមានអំណាចមេបាលើកូន**

១-តាមរយៈការឆ្លើយរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានអះអាងថាៈ សូមប្រគល់សិទ្ធិអំណាចមេបាមកឱ្យខ្លួន លើកូន១នាក់ដោយហេតុថាៈ ចុងចម្លើយពុំដែលផ្តល់ភាពកក់ក្តៅ ពេលវេលា ដល់កូនក្នុងនាមជាឪពុកឡើយ ដោយសារចុងចម្លើយពុំសូវនៅផ្ទះទេ គាត់តែងតែទៅក្រៅជាមួយមិត្តភក្តិសេពគ្រឿងញៀន គ្មានលទ្ធភាពចិញ្ចឹមកូននោះទេ ហើយបច្ចុប្បន្ននេះគាត់ពុំមានការងារច្បាស់លាស់នោះទេ។ ដោយមូលហេតុទាំងអស់នេះនាងខ្ញុំព្រួយបារម្ភអំពីអនាគតកូននៅតូច ហេតុនេះទើបនាងខ្ញុំ សុំឱ្យតុលាការសម្រេចផ្តល់សិទ្ធិអំណាចមេបាឱ្យនាងខ្ញុំលើកូនចំនួនមួយនាក់ដូចបានរៀបរាប់ខាងលើ។ កូនខ្លួននៅតូច ត្រូវការរៀនសូត្រតទៅមុខមានអនាគតវែងឆ្ងាយ ពេលនេះកូនខ្លួននៅជាមួយម្តាយក្មេក ព្រោះពេលការរួច គឺខ្លួននៅជាមួយម្តាយក្មេក ហើយបានម្តាយក្មេក ជួយមើលថែពិតមែន ប៉ុន្តែការផ្គត់ផ្គង់គឺខ្លួនជាអ្នកផ្គត់ផ្គង់ទាំងអស់ ព្រោះសព្វថ្ងៃនេះខ្លួនជាគ្រូពេទ្យឆ្មប នៅមណ្ឌលសុខភាពទន្លេបិទ (ស្រុកត្បូងឃ្មុំ)។

-លោក [redacted] ច័ន្ទវាំសនា អត្តលេខ១៤៣៤ តំណាងដោយអាណត្តិឱ្យដើមចោទ៖ ខ្លួនសូមរក្សាការអះអាងរបស់កូនក្តីខ្លួនទុកដដែល។ ខ្លួនសូមបន្ថែមចំណុចទី២ គឺកូនក្តីខ្លួនមានមុខរបរច្បាស់លាស់ មានការងារត្រឹមត្រូវ ដែលអាចចិញ្ចឹមកូនឱ្យរៀនសូត្របាន ល្អនាពេលអនាគត ហើយអាចផ្តល់ភាពកក់ក្តៅជូនកូនបានផងដែរ។ កូនក្តីខ្លួនជាគ្រូពេទ្យ ជាអ្នកមាន ចំណេះដឹងមួយរូប ដែលអាចទូន្មានកូនបានល្អប្រសើរ



Scanned with CamScanner

ហើយអាចមើលថែកូនបានយូរអង្វែង ដោយកូនក្តី ខ្លួនមិនដែលបានប្រព្រឹត្តបទល្មើសក្នុងសង្គមនោះទេ។ ចំណែកចុងចម្លើយមានប្រវត្តិធ្លាប់ជាប់ពន្ធនាគារ មានការងារមិនច្បាស់លាស់ ចូលចិត្តប្រើអំពើហិង្សាក្នុងគ្រួសារ ហើយលទ្ធភាពជីវភាពនូវមានកម្រិត មិនអាចដាក់កូនឱ្យចូលរៀននៅសាលាល្អបាននោះទេ។ ហេតុនេះ ខ្លួនស្នើសុំតុលាការចេញសាលក្រមផ្តល់កូននោះ មកឱ្យកូនក្តីខ្លួនជាអ្នកមានអំណាចមេបាផងចុះ។

**២-ភាគីចុងចម្លើយបានថ្លែងការណ៍ថា:** ខ្លួនមិនព្រមប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទ លើកូន១នាក់ដោយហេតុថា: ដើមចោទពុំដែលផ្តល់ភាពកក់ក្តៅ និងពេលវេលាដល់កូនក្នុងនាមជាម្តាយឡើយ ដោយសារដើមចោទពុំសូវនៅផ្ទះទេ ហើយពេលកូនឈឺគឺគាត់មិនដែលនៅផ្ទះនោះទេ តែងតែទុកកូនឱ្យម្តាយខ្លួនអ្នកមើលរហូត។ បច្ចុប្បន្ននេះខ្លួនក៏មានការងារច្បាស់លាស់ ហើយអាចចិញ្ចឹមកូនឈ្មោះ [redacted] ចាន់មុនីរាជ ឱ្យបានរៀនសូត្រមានអនាគត។ សព្វថ្ងៃនេះកូនប្រុសខ្លួន កំពុងតែរស់នៅជាមួយម្តាយខ្លួនផងដែរ ដែលគាត់ជួយចិញ្ចឹមតាំងពីតូចមក។ ហេតុនេះខ្លួនស្នើសុំឱ្យតុលាការសម្រេចផ្តល់សិទ្ធិអំណាចមេបាលើកូននេះឱ្យ ខ្ញុំបាទជាអ្នកគ្រប់គ្រងថែរក្សាដូចបានរៀបរាប់ខាងលើ។

ខ្លួនសូមបញ្ជាក់ថាឈ្មោះ [redacted] សុដានី ពុំដែលមានពេលវេលាគ្រប់គ្រាន់ដើម្បីមើលថែកូនរបស់ខ្លួននោះទេ ព្រោះឈ្មោះ [redacted] សុដានី មិនសូវនៅមើលថែកូន ហើយតែងតែចាកចោលផ្ទះ មិនដែលនៅមើលថែកូនពេលកូនឈឺ ហើយចំណុចដែលឈ្មោះ [redacted] សុដានី ថាជាអ្នកផ្គត់ផ្គង់ចិញ្ចឹមកូនតែឯងនោះគឺមិនពិតនោះទេ ពោលគឺខ្លួនតែផ្តល់លុយកាក់ចិញ្ចឹមកូនជានិច្ចមិនដែលអាក់ខានឡើយ។ កន្លងមកក្រោយរៀបការ គឺខ្លួនតែងផ្តល់លុយកាក់ជូនប្រពន្ធខ្លួនទុកដាក់រហូត មិនដែលអាក់ខាននោះឡើយ។ និយាយរួម រឿងដែលដើមចោទអះអាង គឺខ្លួនសូមបដិសេធចោលទាំងស្រុង ខ្លួនមិនដែលគំរាមកំហែងរកសម្លាប់ ឬ ប្រើអំពើហិង្សាលើប្រពន្ធរបស់ខ្លួននោះទេ។

តាមរយៈការអះអាងនេះបញ្ជាក់បានថា ចុងចម្លើយបានទទួលស្គាល់នូវអត្ថិភាព នៃអាពាហ៍ពិពាហ៍ និងមានកូនចំនួន១នាក់នៅក្នុងបន្ទុក។ នៅក្នុងដំណើរការនីតិវិធីតុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ដើមចោទបានទាមទារសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ចាន់មុនីរាជ ព្រោះដើមចោទមានមុខរបរច្បាស់លាស់ មានការងារត្រឹមត្រូវ ដែលអាចចិញ្ចឹមកូនឱ្យរៀនសូត្របាន ល្អនាពេលអនាគត ហើយអាចផ្តល់ភាពកក់ក្តៅជូនកូនបានផងដែរ។ ដើមចោទជាគ្រូពេទ្យ ជាអ្នកមានចំណេះដឹងមួយរូប ដែលអាចទូន្មានកូនបានល្អប្រសើរ ហើយអាចមើលថែកូនបានយូរអង្វែង ដោយដើមចោទមិនដែលបានប្រព្រឹត្តបទល្មើសក្នុងសង្គមនោះទេ។ ចំណែកចុងចម្លើយមានប្រវត្តិធ្លាប់ជាប់ពន្ធនាគារ មានការងារមិនច្បាស់លាស់ ចូលចិត្តប្រើអំពើហិង្សាក្នុងគ្រួសារ ហើយលទ្ធភាពជីវភាពនូវមានកម្រិត មិនអាចចិញ្ចឹមបីបាច់និងឱ្យកូនចូលរៀននៅសាលាល្អបាននោះទេ។ តុលាការយល់ថា ដោយយោងទៅលើស្ថានភាពនៃការរស់នៅសេដ្ឋកិច្ចគ្រួសារ មុខរបររបស់ដើមចោទដែលមានភាពច្បាស់លាស់ និងការផ្តល់ភាពកក់ក្តៅក្នុងនាមជាម្តាយដល់កូន ជាពិសេសពេលនេះក្មេងប្រុសឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស កើតថ្ងៃទីចន្ទ ទី១៧ ធ្នូ ឆ្នាំ២០១៨ បើគិតមកដល់ពេលនេះទើបមានអាយុ៦ឆ្នាំ ប៉ុណ្ណោះ ដែលវ័យនៃអាយុរបស់ក្មេងប្រុសនេះ ត្រូវការជាចាំបាច់ក្នុងការថ្នាក់ថ្នមមើលថែពីម្តាយគ្រប់ពេលវេលា។ ហេតុនេះ តុលាការសម្រេចប្រគល់កូន១នាក់មានឈ្មោះ [redacted] ចាន់មុនីរាជ ភេទប្រុស កើតថ្ងៃទីចន្ទ ទី១៧ ធ្នូ ឆ្នាំ២០១៨ ទៅឱ្យដើមចោទជាអ្នកមានអំណាចមេបា ដោយស្របតាមមាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ហើយចុងចម្លើយដែលមិនមានអំណាចមេបាលើកូន



Scanned with CamScanner

អាចចូលជួបប្រាស្រ័យទាក់ទងកូនដោយសមរម្យ ដោយមិនមានការរាំងស្ទះពីភាគីម្ខាងទៀតឡើយ ស្របតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ដែលសម្រេចអំពីសិទ្ធិ និងករណីរបស់ឪពុកម្ដាយ ដែលមិនរស់នៅជាមួយកូន។

**ឃ-ការវិនិច្ឆ័យអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ភាគីដើមចោទពុំបានស្នើសុំឱ្យខ្លួន ឬឱ្យចុងចម្លើយ ជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដីតុលាការនោះទេ ប៉ុន្តែតុលាការពិនិត្យឃើញថា ក្នុងសំណុំរឿងនេះគប្បីឱ្យភាគីទាំងពីរជាអ្នករ៉ាប់រងលើប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ។ ហេតុនេះ គប្បីសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ និងភាគីចុងចម្លើយ ចំនួនពាក់កណ្ដាលម្នាក់ ស្របតាមស្មារតីនៃមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្ដីសម្រេចបញ្ជាប់**

១_ឱ្យដើមចោទឈ្មោះ [redacted] **សុជាតិ** ភេទស្រី លែងលះពីចុងចម្លើយឈ្មោះ [redacted] **ចាន់រិទ្ធថា** ភេទប្រុស ចាប់ពីពេលនេះតទៅ។

២_កំណត់យកដើមចោទឈ្មោះ [redacted] **សុជាតិ** ភេទស្រី ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **ចាន់មុនីរាជ** ភេទប្រុស កើតថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១៨ ចាប់ពីពេលនេះតទៅ។

- ចុងចម្លើយឈ្មោះ [redacted] **ចាន់រិទ្ធថា** ដែលមិនមានអំណាចមេបាលើកូន អាចចូលជួបប្រាស្រ័យទាក់ទងកូនដោយសមរម្យ ដោយមិនមានការរាំងស្ទះពីភាគីម្ខាងទៀតឡើយ។

៣_កំណត់ឱ្យដើមចោទ និងចុងចម្លើយទទួលបន្ទុកនូវប្រាក់ប្រដាប់ក្ដីពាក់កណ្ដាលម្នាក់។

-សាលក្រមនេះប្រកាសនៅសាលសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ខេត្តត្បូងឃ្មុំ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា ៖** [redacted]

---

*បានសម្រង់ចេញត្រឹមត្រូវតាមច្បាប់ដើម*

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅខេត្តត្បូងឃ្មុំ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

*បានឃើញ*
ខេត្តត្បូងឃ្មុំ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ចៅក្រម**

[redacted]



Scanned with CamScanner